**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Aug-2015, 15:07
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ សាធារណៈ:/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរួមរបស់ក្រុមមេធាវីការពារក្តី ស្តីពីការអនុវត្តមួយចំនួន ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញ**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

Nicholas KOUMJIAN

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**<u>មេធាវីប្រចាំការ៖</u>**

ទូច វរល័ក្ស

Calvin SAUNDERS

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

Beini YE

## I. សេចក្ដីផ្ដើម

1. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) សូមធ្វើការឆ្លើយតបទៅនឹងសំណើរួមរបស់ក្រុមមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន (រួមគ្នាហៅថា “មេធាវីការពារក្ដី”) ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ ទាក់ទិននឹងការអនុវត្តមួយចំនួននៅក្នុងសវនាការ ពាក់ព័ន្ធនឹងការសួរដេញដោលសាក្សី និងអ្នកជំនាញ (“សំណើ”)[1]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដោយមានកង្វល់ពីប្រសិទ្ធផលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្ដល់ឱកាសដល់សាក្សីឲ្យរម្លឹកការចងចាំរបស់ពួកគេ ដោយពិនិត្យមើលចម្លើយមុនៗរបស់ពួកគាត់[2]។ អង្គជំនុំជម្រះបានណែនាំឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (“WESU”) ផ្ដល់ចម្លើយមុនៗទៅឲ្យសាក្សីនីមួយៗ ដើម្បីឲ្យពួកគាត់អាចពិនិត្យមើលចម្លើយទាំងនោះ មុនពេលមកផ្ដល់សក្ខីកម្ម[3]។

3. នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់លម្អិតបន្ថែមទៀតថា ការអនុវត្តនេះមានគោលបំណងដើម្បីធានាថា សាក្សីអាចរម្លឹកពីការចងចាំរបស់ពួកគាត់ចំពោះអ្វីដែលពួកគាត់បាននិយាយពីមុន ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ដែលជាញឹកញយ បានធ្វើឡើង “កាលពីប៉ុន្មានខែមុន”[4]។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងបន្ថែមថា ចម្លើយនានាដែលបានលើកឡើងនឹងមិនត្រូវយកមកប្រើប្រាស់ក្នុងតុលាការដោយសាក្សីទេ ហើយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នឹងយកចេញពីពួកគាត់វិញ នៅពេលពួកគាត់អានចប់[5]។ លើសពីនេះទៀត សាក្សីនឹង

---

[1] សំណើរួមគ្នានៃមេធាវីការពារក្ដីសុំឲ្យវិលមកប្រកាន់យកការអនុវត្តមួយចំនួនពាក់ព័ន្ធនឹងការផ្ដល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ ឯកសារ **E355** ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥។

[2] ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ **E141** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៧។

[3] *ដូចយោងខាងលើ*។

[4] ឯកសារ **E1/16.1** ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៥១។

[5] *ដូចយោងខាងលើ*។

មិនអាចប្រើប្រាស់ចម្លើយណាមួយដែលពួកគាត់មាន ដើម្បីរម្លឹកការចងចាំរបស់ពួកគាត់នៅក្នុងតុលាការទេ[6]។

4. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ យោងតាមសំណើសុំការបំភ្លឺពីសហព្រះរាជអាជ្ញា ស្តីពីការប្រើប្រាស់ឯកសារក្នុងអំឡុងពេលសួរដេញដោលសាក្សីនៅក្នុងសវនាការ[7] អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីជូនដំណឹងមួយដល់ភាគីទាក់ទិននឹងនីតិវិធីថ្មីសម្រាប់សួរសំណួរ[8]។ អង្គជំនុំជម្រះបានសម្រេចថា៖

> "អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកភាគីថា ដើម្បីផលប្រយោជន៍នៃការធានានូវភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីនោះ នាពេលថ្មីៗនេះ អង្គជំនុំជម្រះបានចាប់ផ្តើមសួរសំណួរទៅសាក្សីម្នាក់ៗដែលមកផ្តល់សក្ខីកម្មថាតើសាក្សីបានពិនិត្យមើលឡើងវិញនូវចម្លើយដែលខ្លួនបានផ្តល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ដែរឬទេ ហើយថាតើចម្លើយទាំងនេះជាចម្លើយត្រឹមត្រូវដែលសាក្សីបានឆ្លើយនៅដំណាក់កាលស៊ើបអង្កេត មែន ឬយ៉ាងណា។ ក្នុងករណីដែលសាក្សីគូសបញ្ជាក់ ថាខ្លួនពិតជាចាំចម្លើយរបស់ខ្លួន ហើយខ្លឹមសារនៃចម្លើយដូចដែលបានកត់ត្រានៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច។ស មានភាពត្រឹមត្រូវ ភាគីមិនត្រូវស្នើផ្ទួនៗសុំឱ្យសាក្សីបញ្ជាក់អំពីការពិតនេះ ឬព្យាយាមបង្ខំសាក្សីឱ្យរៀបរាប់ឡើងវិញអំពីខ្លឹមសារនៃចម្លើយនោះឡើយ។ ជំនួសមកវិញ ភាគីគួរគប្បីផ្តោតការខិតខំរបស់ខ្លួនលើសំណួរផ្សេងៗ (ឧទាហរណ៍ សំណួរស្តីពីបញ្ហានានាដែលពុំស្ថិតនៅក្នុងខ្លឹមសារនៃចម្លើយ) ឬ ការជំទាស់តវ៉ាជាក់លាក់ទៅនឹងភាពអាចជឿជាក់បាននៃចម្លើយ ឬភ័ស្តុតាងរបស់សាក្សី"[9]។

[6] *ដូចយោងខាងលើ*។

[7] សំណើរបស់សហព្រះរាជអាជ្ញា សុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារ ក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី ឯកសារ **E201** ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២។

[8] សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានាក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី ឯកសារ **E201/2** ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ("អនុស្សរណៈរបស់ អ.ជ.ស.ដ ស្តីពីការប្រើប្រាស់ឯកសារ")។

[9] អនុស្សរណៈរបស់ អ.ជ.ស.ដ ស្តីពីការប្រើប្រាស់ឯកសារ ទំព័រ ១។

5. នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[10] ប្រឆាំងនឹងសាលក្រម[11] ដែលសហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥[12]។ សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា បានជំទាស់ទៅនឹងការអនុវត្តមួយចំនួននៅពេលជំនុំជម្រះ *ក្នុងចំណោមនោះ* បានចោទប្រកាន់ពីកំហុសអង្គច្បាប់ ក្នុងការអនុញ្ញាតឲ្យសាក្សីអាចពិនិត្យមើលចម្លើយមុនៗ មុនពេលផ្ដល់សក្ខីកម្ម និងឆ្លើយតបសំណួរនាំមុខនានាដែលផ្អែកលើចម្លើយទាំងនោះ[13]។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ក៏បានជំទាស់ស្រដៀងគ្នាដែរទៅនឹងការអនុវត្តទាំងនេះ[14]។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងកំហុសដែលត្រូវបានចោទប្រកាន់ទាំងនេះ នៅក្នុងសារណាចម្លើយតបរបស់ខ្លួន[15]។

6. នៅថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៥ មេធាវីការពារក្ដី ខៀវ សំផន បានចុះកំណត់ហេតុការជំទាស់របស់ខ្លួនទៅនឹងការអនុវត្តរបស់សាក្សីដែលអានលើចម្លើយមុនៗរបស់ពួកគាត់ ដោយលើកជាទឡ្ហីករណ៍ថា វាផ្លាស់ប្ដូរសក្ខីកម្មរបស់ពួកគាត់នៅក្នុងសវនាការ[16]។ ដោយយោងដល់ទឡ្ហីករណ៍នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្ដី នួន ជា ក៏បានជំទាស់ទៅនឹងការអនុវត្តនេះដែរ ទាក់ទិននឹងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ដោយសារវា "រារាំងដល់ការស្វែងរកការពិត"[17]។

7. អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ការជំទាស់ទាំងនេះ និងបានសម្រេចបន្តការអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ ដែលបានអនុញ្ញាតឲ្យសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី អានចម្លើយមុនៗ

---

[10] បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ឯកសារ **F16** ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា")។ សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ឯកសារ **F17** ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន")។

[11] សាលក្រមលើសំណុំរឿង ០០២/០១ ឯកសារ **E313** ចុះថ្ងៃទី ៧ សីហា ឆ្នាំ ២០១៤ ("សាលក្រម")។

[12] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F17/1** ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ("សារណាចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

[13] សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា មូលដ្ឋានទី ១៥ ដល់ មូលដ្ឋានទី ១៦ កថាខណ្ឌ ១៣៥ ដល់ ១៤៧។

[14] សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៦។

[15] សារណាចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨១ ដល់ ៨៣។

[16] ឯកសារ **E1/247.1** ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៦។

[17] *ដូចយោងខាងលើ* ទំព័រ ២៧។

របស់ពួកគាត់ ដើម្បីរម្លឹកការចងចាំ មុនពេលផ្ដល់សក្ខីកម្មនៅក្នុងតុលាការ[18]។ ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យមេធាវីការពារក្ដីដាក់ការជំទាស់ និងសំណើរបស់ខ្លួនជាលាយលក្ខណ៍អក្សរ[19]។

8. នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ មេធាវីការពារក្ដី នួន ជា បានដាក់ការជំទាស់របស់ខ្លួន *ក្នុងចំណោមបញ្ហាផ្សេងៗ* មេធាវីបានជំទាស់ទៅនឹងការអនុវត្តដែលអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យទៅលើចម្លើយមុនៗរបស់ពួកគាត់ មុនពេលផ្ដល់សក្ខីកម្ម និងឆ្លើយសំណួរដោយផ្អែកលើចម្លើយទាំងនោះ[20]។ សហមេធាវីនាំមុខបានជំទាស់ទៅនឹងសំណើនេះ ដោយផ្អែកលើមូលដ្ឋានថាសំណើនេះមិនត្រឹមតែផ្ទុយទៅនឹងបទប្បញ្ញត្តិជាក់លាក់នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ តែវាក៏នឹងជាការផ្លាស់ប្ដូរយ៉ាងធំធេងចំពោះសិទ្ធិសំខាន់ និងសិទ្ធិផ្នែកដំណើរការនីតិវិធីដែលបានអនុញ្ញាតដល់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។

9. នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្ដីណែនាំស្ដីពីកិច្ចនីតិវិធីនៃសវនាការលើបណ្ដឹងសាទុក្ខ ដែលទាក់ទិននឹងការសួរដេញដោលសាក្សីបីនាក់ ដែលមេធាវីការពារក្ដី នួន ជា បានស្នើឡើង។ អង្គជំនុំជម្រះតុលាការកំពូលបានហាមឃាត់ភាគីមិនឲ្យសួរ "សំណួរដែលមានលក្ខណៈនាំមុខ នៅក្នុងប្រធានបទដែលមានលក្ខណៈចម្រូងចម្រាស លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំជម្រះ" និងបានណែនាំឲ្យភាគីមិនឲ្យសួរសំណួរសាក្សីដោយ "គ្រាន់តែអាននូវអត្ថបទនៃចម្លើយពីមុនរបស់សាក្សីឲ្យគាត់ស្ដាប់ ហើយធ្វើការបញ្ជាក់នោះទេ"[21]។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយមុនៗដើម្បី "ល្បងលើភាពអាចជឿជាក់បានរបស់សាក្សី ឬបញ្ជាក់អំពីភាពមិនស្របគ្នារវាងចម្លើយផ្សេងៗ"[22]។ សេចក្ដីណែនាំទាំងនេះត្រូវបានចេញដោយមិនប៉ះពាល់ដល់មូលដ្ឋាននៃបណ្ដឹងសាទុក្ខដែលបានលើកឡើងដោយមេធាវីការពារក្ដីទេ

[18] *ដូចយោងខាងលើ* ទំព័រ ២៨។

[19] *ដូចយោងខាងលើ*។

[20] សំណើរបស់ នួន ជា ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួនដែលត្រូវមាន នៅពេលសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-271 នាពេលខាងមុខ និង សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀតក្នុងសំណុំរឿង ០០២/០២ ជាទូទៅ ឯកសារ **E336** ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥។

[21] សេចក្ដីណែនាំស្ដីពីកិច្ចនីតិវិធីនៃសវនាការ ឯកសារ **F26** ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៥។

[22] *ដូចយោងខាងលើ*។

ដោយអង្គជំនុំជម្រះបានគូសបញ្ជាក់ថា សេចក្តីណែនាំទាំងនេះ "ពុំមានអានុភាពទៅលើទឡ្ហីករណ៍ណាមួយនៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយជនជាប់ចោទឡើយ"[23]។

10. នៅថ្ងៃទី ២៧ ដល់ ២៨ ខែ កក្កដា ឆ្នាំ ២០១៥ បញ្ហានៃពិនិត្យទៅលើចម្លើយមុនៗដោយសាក្សី ត្រូវបានលើកឡើងម្តងទៀតនៅក្នុងតុលាការ បន្ទាប់ពីមានការសម្រេចដោយផ្ទាល់មាត់ពីអង្គជំនុំជម្រះសាលាដំបូង[24]។

## III. ច្បាប់ជាធរមាន

11. វិធាន ៨៥(១) នៃវិធានផ្ទៃក្នុងចែងថា ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការ "អាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត"[25]។

12. វិធាន ៩១(១) នៃវិធានផ្ទៃក្នុងចែងថា "ចៅក្រម អាចសួរសំណួរ ហើយសហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវី ក៏ត្រូវបានអនុញ្ញាតឲ្យសួរសំណួរ ដោយមានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះសាលាដំបូង"។ វិធាននេះបន្ថែមថា "សំណួរទាំងអស់ត្រូវធ្វើតាមរយៈប្រធានអង្គជំនុំជម្រះសាលាដំបូង"។ វិធាន ៩១(៣) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ភាគីទាំងអស់ និង មេធាវីអាចជំទាស់ទៅនឹងការស្តាប់ចម្លើយសាក្សី ដែលកំពុងដំណើរការ ប្រសិនបើខ្លួនយល់ថាចម្លើយរបស់សាក្សីនោះមិនសម្តែងឲ្យឃើញការពិត ។

## IV. ការពិភាក្សា

13. សហមេធាវីនាំមុខឆ្លើយតបទៅនឹងសំណើនេះ ដោយសារវាពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់សហមេធាវីនាំមុខក្នុងការសម្របសម្រួលជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីនីតិវិធីនៃការសួរ

---

[23] *ដូចយោងខាងលើ* ទំព័រ ៤។

[24] សេចក្តីព្រាងប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥ ទំព័រ ៦៣ ដល់ ៦៤ (ភាសាអង់គ្លេស)។ សេចក្តីព្រាងប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ (ភាសាបារាំង) ទំព័រ ៦៦ ដល់ ៦៧។

[25] *ប្រៀបធៀប* សំណៅជាភាសាបារាំងនៃវិធាន ៨៥(១) នៃវិធានផ្ទៃក្នុង៖ « Le Président de l'audience dirige les débats et facilite l'intervention des autres juges. Il veille au libre exercice des droits de la défense. Après consultation des autres juges, le Président peut exclure des débats tout ce qui tend à les prolonger inutilement sans contribuer à la manifestation de la vérité. » (គូសបញ្ជាក់បន្ថែម)។

ដេញដោលសាក្សី និងអ្នកជំនាញ ដែលកើតចេញពីការទទួលខុសត្រូវជាសំខាន់របស់ពួកគេចំពោះតុលាការក្នុងការផ្តល់ការអះអាង និងយុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងនៅចំពោះមុខតុលាការអំពីផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយនោះក្នុងអំឡុងពេលជំនុំជម្រះ[26]។ លើសពីនេះទៀត នៅក្នុងករណីនេះ លក្ខណៈនៃកិច្ចដំណើរការនីតិវិធីជាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅក្នុងចំណោមផលប្រយោជន៍ និងការព្រួយបារម្ភផ្សេងទៀត អាស្រ័យទៅលើភាពឆាប់រហ័ស និងប្រសិទ្ធផលនៃការជំនុំជម្រះ។

14. មេធាវីការពារក្តីផ្អែកសំណើរបស់ខ្លួនទៅលើសេចក្តីណែនាំនានាដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញក្នុងអំឡុងពេលស្តាប់សក្ខីកម្មសាក្សីបន្ថែមលើបណ្តឹងសាទុក្ខ[27]។ ហេតុនេះ តាំងពីដំបូងមក សហមេធាវីនាំមុខបានលើកឡើងថា សំណើនេះពុំមានមូលដ្ឋានទេ។ ទីមួយ សេចក្តីណែនាំទាំងនេះត្រូវបានចេញ ដោយមិនប៉ះពាល់ដល់មូលដ្ឋាននៃបណ្តឹងសាទុក្ខដែលបានលើកឡើងដោយមេធាវីការពារក្តីទេ[28] ហើយអង្គជំនុំជម្រះតុលាការកំពូលក៏មិនបានចេញសេចក្តីសម្រេចដែលមានសំអាងហេតុបញ្ជាក់ពីមូលហេតុដែលថាការអនុវត្តទាំងនេះត្រូវបានហាមឃាត់ដោយសេចក្តីណែនាំទាំងនេះទេ។ ដោយមិនគិតដល់ថាតើការអនុវត្តឆ្លុះបញ្ចាំងនូវទស្សនាទានត្រឹមត្រូវអំពីកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ឬយ៉ាងណានោះ ការសន្និដ្ឋានអំពីសំអាងហេតុសម្រាប់សេចក្តីណែនាំទាំងនេះគឺជាការប៉ាន់ស្មានប៉ុណ្ណោះ នៅក្នុងដំណាក់កាលនេះ។ សហមេធាវីនាំមុខលើកឡើងថា ការផ្លាស់ប្តូរការអនុវត្តដែលបានបង្កើតឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយគ្រាន់តែសំអាងលើមូលដ្ឋានទាំងនេះ មិនមែនជាការត្រឹមត្រូវទេ។ ហេតុនេះ សំណើគួរត្រូវបានបដិសេធដោយផ្អែកលើចំណុចនេះ។

15. សហមេធាវីនាំមុខលើកទទ្បឹករណ៍ថា ដោយផ្អែកលើអំណានរួមនៃវិធានផ្ទៃក្នុង និងការអនុវត្តដែលត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង វាច្បាស់ណាស់ថា អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការជំទាស់ ដោយផ្អែកលើមូលដ្ឋានថា សំណួរដែលត្រូវសួរគ្មាន

---

[26] *សូមមើល* វិធាន ១២*ស្ទួនពីរ* (៦) អានរួមជាមួយវិធាន ១២*ស្ទួនពីរ*(៥)(ខ) នៃវិធានផ្ទៃក្នុង។

[27] សំណើ កថាខណ្ឌ ៩ ដល់ ១១ *យោងដល់* សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ ឯកសារ **F26** ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥។

[28] សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ ឯកសារ **F26** ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៥។

ប្រយោជន៍ចំពោះការស្វែងរកការពិត និង/ឬពន្យារពេលដែលកិច្ចដំណើរការនីតិវិធីដោយមិនចាំបាច់។

16. លើសពីនេះទៀត សម្រាប់គោលបំណងនៃសារណាតបនេះ សហមេធាវីនាំមុខកត់សម្គាល់ថា បញ្ហាចំនួនពីរដែលត្រូវបានលើកឡើងដោយសំណើដែលទាក់ទិននឹងការសួរសំណួរនាំមុខ និងការអនុវត្តនៃការពិនិត្យទៅលើចម្លើយមុនៗ មុននឹងផ្តល់សក្ខីកម្ម ទោះបីមានការពាក់ព័ន្ធក៏ដោយ ក៏ជាបញ្ហាដោយឡែក ហើយត្រូវបានលើកឡើងដាច់ដោយឡែកពីគ្នា នៅក្នុងសារណាតបនេះ។

## *(ក) ការពិនិត្យលើចម្លើយពីមុនៗដោយសាក្សី*

17. សហមេធាវីនាំមុខលើកឡើងថា ដើម្បីហាមឃាត់សាក្សីមិនឱ្យអាចចម្លើយរបស់ពួកគាត់ដែលត្រូវបានស្តាប់ពីមុន ដែលនៅក្នុងករណីជាច្រើន បានធ្វើឡើងនៅពេលជាច្រើនឆ្នាំមកហើយ ដែលទាក់ទិននឹងព្រឹត្តិការណ៍នានាដែលបានកើតឡើងកាលពីប៉ុន្មានទសវត្សរ៍មកហើយ នឹងបណ្តាលឱ្យការពន្យារពេលដែលមិនចាំបាច់ ក្នុងការសួរដេញដោលសាក្សី ដោយសារតែការបាត់បង់ការចងចាំ អាយុកាល និងសុខភាពរបស់សាក្សី។ ដោយពិចារណាថា គោលការណ៍ចម្បងដែលគ្រប់គ្រងលើដំណើរការស្តាប់សក្ខីកម្មនៅ អ.វ.ត.ក គឺ "ការស្វែងរកការពិត"[29] និងការបញ្ចៀសនូវ "ការពន្យារពេលដល់ការជំនុំជម្រះដែលមិនចាំបាច់"[30] នោះ សហមេធាវីនាំមុខលើកឡើងថា ពុំមានមូលដ្ឋានសមហេតុផលណាមួយក្នុងការផ្លាស់ប្តូរការអនុវត្តបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទេ។

18. ទោះយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានហាមឃាត់មិនឱ្យប្រើប្រាស់កំណត់ហេតុផ្ទាល់ខ្លួននៃចម្លើយមុនៗរបស់សាក្សី សម្រាប់ការពិនិត្យឡើងវិញទេ ហើយផ្ទុយទៅវិញ បានតម្រូវឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញផ្តល់ឱ្យពួកគាត់នូវសំណៅផ្លូវការនៃកំណត់ហេតុស្តាប់ចម្លើយមុនៗរបស់ពួកគាត់សម្រាប់យកទៅពិនិត្យ[31]។ លើសពីនេះទៀត សាក្សីមិនត្រូវបានអនុញ្ញាតឱ្យប្រើ

---

[29] វិធាន ៨៥(១), ៩១(៣) នៃវិធានផ្ទៃក្នុង។

[30] វិធាន ៨៥(១) នៃវិធានផ្ទៃក្នុង។

[31] ឯកសារ **E1/16.1** ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៤៧៖ "អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការអនុវត្ត [sic] នៅដំណាក់កាលស៊ើបសួរដែលថាសាក្សីត្រូវបានផ្តល់ជូននូវឯកសាររបស់ខ្លួនមួយច្បាប់។ ការធ្វើដូច្នេះ ដើម្បីធានាធ្វើយ៉ាងណាឱ្យសាក្សីគាត់អាចចងចាំឡើងវិញនូវអ្វីដែលគាត់បានលើកឡើងកាលពីប៉ុន្មានឆ្នាំមុន។ ចម្លើយទាំងអស់នោះ គឺមិនអាចប្រើប្រាស់

ប្រាស់ចម្លើយមុនៗរបស់ពួកគាត់ក្នុងអំឡុងពេលសួរដេញដោលនៅក្នុងតុលាការ ដើម្បីរម្លឹកការចងចាំរបស់ពួកគេទេ[32] លើកឡើងតែករណីដែលភាគីសួរដេញដោលយកមកប្រើប្រាស់[33]។ សហមេធាវីនាំមុខលើកឡើងថា ការអនុវត្តបច្ចុប្បន្នបង្ហាញពីការសម្របសម្រួលគ្នារវាងផលប្រយោជន៍ពីរដែលប្រកួតប្រជែងគ្នា នៅក្នុងករណីពិសេសទាំងនេះ ពោលគឺ ការពន្យារពេលនៃការជំនុំជម្រះដែលមិនចាំបាច់ និងការស្វែងរកការពិត។ ហេតុនេះ សហមេធាវីនាំមុខសូមជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាច្រានចោលសំណើ ទាក់ទិននឹងការពិនិត្យលើចម្លើយមុនៗដោយសាក្សី។

### *(ខ) សំណួរនាំមុខ*

19. សំណើបានជំរុញអង្គជំនុំជម្រះសាលាដំបូងឲ្យហាមឃាត់ភាគីមិនឲ្យចោទសំណួរទៅសាក្សីដែលអាចនាំទៅដល់ចម្លើយចំពោះបញ្ហាដែលត្រូវបានជំទាស់ដោយភាគីនានាទេ[34]។

20. នៅក្នុងន័យនេះ សហមេធាវីនាំមុខបានបកស្រាយសំណើថា ស្នើឲ្យ (១) អង្គជំនុំជម្រះសាលាដំបូងដាក់ការហាមឃាត់ជាទូទៅចំពោះភាគី មិនឲ្យសួរសំណួរនាំមុខ ឬ (២) អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យភាគីនានា ធ្វើការជំទាស់ដោយមានហេតុផលចំពោះសំណួររបស់ភាគីដទៃដែលហាក់បីដូចជា "នាំមុខ" ឬផ្តល់ចម្លើយឲ្យ។ សហមេធាវីនាំមុខបានឆ្លើយតបទៅនឹងការសន្មតទាំងពីរនេះ។

21. ពាក់ព័ន្ធទៅនឹងចំណុចទីមួយ សហមេធាវីនាំមុខជំទាស់ថា ការអនុវត្តបែបនេះនឹងផ្ទុយពីនីតិវិធីនៅអ.វ.ត.ក។

22. សហមេធាវីនាំមុខសូមលើកឡើងថា ជាគោលការណ៍ ទស្សនទាន "សំណួរនាំមុខ" មិនមាននៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡើយ ដោយហេតុថានៅក្នុងប្រព័ន្ធច្បាប់នេះ ចៅក្រមជាអ្នកដឹកនាំកិច្ចស៊ើបសួរស្វែងរកភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធី

---

យកមកដាក់នៅក្នុងតុលាការនោះទេ គឺយើងនឹងដកហូតមកវិញនៅពេលដែលសាក្សី ឬអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានប្រើប្រាស់រួចរាល់ហើយ ហើយពួកគាត់មិនអាចប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយដែលពួកគាត់មានក្នុងដៃ ដើម្បីរម្លឹកឡើងវិញពីការចងចាំ នៅក្នុងតុលាការបានទេ"។

[32] *ដូចយោងខាងលើ*។

[33] *សូមមើល ឧទាហរណ៍* ឯកសារ **E1/268.1** ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ ១៦។ ឯកសារ **E1/280.1** ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥ ទំព័រ ១៦។ ឯកសារ **E1/296.1** ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៦៦ ដល់ ៦៧។

[34] សំណើ, ទំព័រ ៥។

ហើយប្រព័ន្ធច្បាប់នេះពុំមានវិធានចែងអំពីភ័ស្តុតាងឡើយ មិនតែប៉ុណ្ណោះ រាល់ភ័ស្តុតាងទាំងឡាយត្រូវបានចាត់ទុកថាអាចទទួលយកបានផងដែរ[35]។

23. នៅក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (common law) គោលដៅចម្បងនៃការកំហិតការសួរសំណួរនាំមុខក្នុងពេលសួរដេញដោលសាក្សីគឺដើម្បីការពារកុំឲ្យក្រុមប្រឹក្សាជំនុំជម្រះ និង/ឬចៅក្រម ដែលស្តាប់ភស្តុតាងពាក់ព័ន្ធរឿងក្តីរបស់ភាគីជាលើកដំបូង នៅក្នុងសាលសវនាការសាធារណៈ មានភាពទោទន់ទៅតាមភ័ស្តុតាងដែលបង្ហាញដោយភាគី និងដើម្បីជៀសវៀងកុំឲ្យសាក្សីលង់ទៅក្នុងវិធីសាស្ត្រនៃសំណួរនាំមុខនោះ។ លើសពីនេះទៀត រឿងក្តីរបស់មេធាវីការពារក្តីពឹងផ្អែកជាសំខាន់ទៅលើរឿងក្តីដែលត្រូវបង្ហាញដោយរដ្ឋអាជ្ញា នៅចំពោះមុខចៅក្រម (ឬក្រុមប្រឹក្សាជំនុំជម្រះ)។ មេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យសួរសំណួរនាំមុខ ចំពោះសាក្សីរបស់រដ្ឋអាជ្ញា បន្ទាប់ពី “ការសួរសាក្សីរបស់ មេធាវី” ដើម្បីអនុវត្តការដេញដោលដើម្បីស្វែងរកការពិតនៅក្នុងតុលាការក្នុងប្រព័ន្ធច្បាប់កុំមិនឡ និងជួយដល់ចៅក្រម និងក្រុមប្រឹក្សាជំនុំជម្រះ ក្នុងការសម្រេចសាលក្រមរបស់ខ្លួនអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ វិធានប្រហែលគ្នានេះត្រូវអនុវត្តចំពោះសាក្សី ដែលស្នើឡើងដោយមេធាវី ការពារក្តីនៅចំពោះមុខតុលាការ នៅពេលដែលមេធាវីការពារក្តីបង្ហាញរឿងក្តីរបស់ខ្លួន។

24. ប៉ុន្តែ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដូចជារឿងក្តីនៅ អ.វ.ត.ក ចៅក្រមដែលសម្រេចទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទ អាចចូលពិនិត្យមើលសំណុំរឿងភ្លាមៗក្រោយពេលចៅក្រមទទួលបានសំណុំរឿង[36]។ ពួកគាត់បានដឹងពីអង្គហេតុ និងកិច្ចស៊ើបអង្កេតពាក់ព័ន្ធនៅចំពោះមុខខ្លួន។ ពួកគាត់មិនត្រឹមតែមានភារកិច្ចស្វែងរកការពិតនៃ “រឿងក្តីរបស់ព្រះរាជអាជ្ញា” ប៉ុណ្ណោះនោះទេ ប៉ុន្តែពួកគាត់ត្រូវស្វែងរកការពិតទាក់ទងអង្គហេតុដែលពួកគាត់បានទទួលទៀត។ ដោយសារតែហេតុផលនេះទើបចៅក្រមខ្លួនឯងមានសេរីភាពក្នុងការសួរសំណួរ[37]។ អ្វីដែលសំខាន់នោះគឺថា អង្គហេតុទាំងអស់នេះបានកើតចេញពីការស៊ើបអង្កេតឯករាជ្យ ទាំងទៅលើព័ត៌មានដាក់បន្ទុក និងព័ត៌មានដោះបន្ទុក ដោយសហចៅក្រមស៊ើបអង្កេត។

---

[35] សូមប្រៀបធៀបជាមួយវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងដែលចែងថា៖ [លើកលែងតែមានបទបញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួល យក។]

[36] វិធាន ៦៩ នៃវិធានផ្ទៃក្នុង អាចគួបជាមួយវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។

[37] វិធាន ៩១(២) នៃវិធានផ្ទៃក្នុង។

25. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ម្តងហើយម្តងទៀតថា សាក្សីដែលត្រូវបានកោះហៅមកចំពោះមុខខ្លួន ចាំបាច់ត្រូវចាត់ទុកថាជាសាក្សីរបស់អង្គជំនុំជម្រះ។ ភាគីនានាមិនមានសិទ្ធិជាស្វ័យប្រវត្តិក្នុងការសួរសំណួរក្នុងពេលសួរដេញដោលឡើយ ហើយសំណួរទាំងអស់ដែលត្រូវសួរដោយសហព្រះរាជអាជ្ញា និងមេធាវី គឺត្រូវបានតម្រូវឲ្យសួរ "តាមរយៈប្រធានអង្គជំនុំជម្រះ"[38]។ ភាគីអាចត្រឹមតែជំទាស់ នៅពេលដែលសំណួរមិន "អាចនាំដល់ការស្វែងរកការពិត"[39] ហើយមិនបំពេញតាមលក្ខណវិនិច្ឆ័យ ដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ការអនុវត្តនៅ អ.វ.ត.ក ដែលបានវិវឌ្ឍន៍នៅក្នុងបរិបទនៃសំណួរនាំមុខ យកតាមគោលការណ៍នេះ មិនមែនតាមគោលគំនិតដែលថា សំណួរនាំមុខបានភ្ជាប់ជាមួយនឹង "ការសួរសំណួរសាក្សីរបស់ មេធាវី" តទល់ "ការសួរដេញដោលដោយភាគីផ្សេង" ឡើយ។ ហេតុដូច្នេះ សហមេធាវីនាំមុខលើកឡើងថា ការហាមឃាត់ជាទូទៅបែបនេះនៅ អ.វ.ត.ក នឹងធ្វើឲ្យប៉ះពាល់ដល់នីតិវិធីជជីកសួរដោយចៅក្រមដែលកំពុងតែអនុវត្តនាពេលនេះ។

26. ពាក់ព័ន្ធទៅនឹងការសន្មតទីពីរ ដែលថា ភាគីត្រូវបានអនុញ្ញាតឲ្យធ្វើការជំទាស់ដោយមានសំអាងហេតុ ដោយផ្អែកលើមូលដ្ឋានថា សំណួរមានលក្ខណៈផ្តល់ចម្លើយ សហមេធាវីនាំមុខលើកឡើងថា ការអនុវត្តបែបនេះត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូងរួចហើយ។ តាមរយៈការប្រើប្រាស់សិទ្ធិពិសេសរបស់គាត់អនុលោមតាមវិធានទាំងអស់នេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ បានសម្រេចដោយផ្ទាល់មាត់ចំពោះការសួរសាក្សី តាមរយៈសំណួរនាំមុខ ព្រមទាំងចំពោះភាពចាំបាច់ក្នុងការសួរសំណួរបើក និងសំណួរសាមញ្ញ[40]។ នៅក្នុងសំណុំរឿង ០០២/០២ ប្រធានអង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចទៅលើការជំទាស់ដោយ

---

[38] វិធាន ៩១(២) នៃវិធានផ្ទៃក្នុង (គូសបញ្ជាក់បន្ថែម)។

[39] វិធាន ៩១(៣) នៃវិធានផ្ទៃក្នុង។

[40] *សូមមើលជាឧទាហរណ៍* ឯកសារ **E1/54.1** ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ៨០៖ ចៅក្រម Cartwright ក្នុងនាមប្រធានអង្គជំនុំជម្រះ៖ "សហព្រះរាជអាជ្ញាត្រូវបានស្នើសុំធ្វើយ៉ាងណា ឲ្យសួរសំណួរកុំឲ្យជាសំណួរនាំមុខ គឺអាចសួរឲ្យបញ្ជាក់បំភ្លឺបាន ឧទាហរណ៍ ដើម្បីឆ្លើយតបទៅនឹងសំណួរមុន សាក្សីនិយាយថា ប៉ង់ ជាអ្នកប្រាប់អំពីឈ្មោះទាំងប្រាំពីរដែលជាសមាជិកអចិន្ត្រៃយ៍។ បន្ទាប់មក គឺអាចសួរតបាន។ វាសំខាន់សម្រាប់អង្គជំនុំជម្រះ ឲ្យយល់ឲ្យបានច្បាស់ និងភាគីផងដែរ ធ្វើយ៉ាងណាពេលសួរ កុំឲ្យជាសំណួរនាំមុខ។ ដូច្នេះហើយ ខ្ញុំស្នើសុំឲ្យសហព្រះរាជអាជ្ញានេះ សួរឲ្យបានច្បាស់លាស់ ហើយកុំឲ្យនាំសួរសំណួរនាំមុខ កុំឲ្យយកពាក្យសម្តីទៅឲ្យសាក្សីឆ្លើយ"។ ឯកសារ **E1/64.1** ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១២, ទំព័រ ១០៖ ចៅក្រម Cartwright ក្នុងនាមប្រធានអង្គជំនុំជម្រះ៖ "មិនអនុញ្ញាតទេ ព្រោះជាសំណួរនាំមុខ"។

មានសំអាងហេតុ ដែលលើកឡើងដោយភាគីនានា នៅក្នុងកាលៈទេសៈជាច្រើន ដូចករណីខាងក្រោម៖

ឧទាហរណ៍ទី ១៖

"ខ្ញុំសួរពីចន្លោះ ខ្ញុំអត់សួរពីក្នុងរង្វង់ចំណោមអ្នកជាប់ទោសប្រាំនាក់នោះទេ គឺខ្ញុំសួរពីចន្លោះ ពីរវាងអ្នកប្រាំនាក់ទីមួយ ទៅអ្នកប្រាំនាក់ទី២ទៀតនោះ ដែលលោកឆ្លើយពីដើមមកថា មិនលើសពី ២ម៉ែត្រ ហើយខ្ញុំចង់បញ្ជាក់ឡើងវិញជូនអង្គជំនុំជម្រះថា អ្នកទោសដែលគេដាក់ក្នុងចន្លោះប្រាំនាក់ហ្នឹង គឺគេដាក់បញ្ចៀតគ្នា គឺថាអត់មានចន្លោះទេតែនៅពេលដែលគ្រប់ប្រាំនាក់ហើយ ត្រូវដាក់ប្រាំនាក់ទៀត គឺអាចមានចន្លោះពីមួយម៉ែត្រកន្លះ ឬក្រោមពីរម៉ែត្រ ហ្នឹងតាមសក្ខីកម្មរបស់លោក។ ខ្ញុំនិយាយអីចឹងត្រឹមត្រូវទេ?

ប្រធានអង្គជំនុំ៖ បន្តទៀត! មិនបាច់ឆ្លើយតបទេ។ តសំណួរផ្សេងទៀត! សំណួរច្រំដែល សំណួរដឹកមុខថែមទៀតផង"[41]។

ឧទាហរណ៍ទី ពីរ៖

ស៖ តើខ្ញុំនិយាយជាការត្រឹមត្រូវទេ មានន័យថាលោកស្រីរៀបការដោយបង្ខំ ជាមួយមនុស្សដែលលោកស្រីស្អប់ លោកស្រីមិនស្គាល់ច្បាស់ទាល់តែសោះ?

ប្រធានអង្គជំនុំ៖ សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា

លោក គង់ សំអុន៖ បាទ សូមទោសលោកប្រធាន ខ្ញុំ គង់ សំអុន។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ ហើយខ្ញុំយល់ថាជាសំណួរនាំមុខ សាក្សីលោកបានឆ្លើយបញ្ជាក់ហើយថា គាត់រៀបការដោយមានការបង្ខំចិត្ត មិនមែនជាការរៀបការដោយបង្ខំទេ។ ហើយតំណាងសហព្រះរាជអាជ្ញាព្យាយាមលើកសំណួរនេះច្រំដែល ពីរបីដងដើម្បីឲ្យសាក្សីឆ្លើយបញ្ជាក់ទៅលើពាក្យនេះ ហើយការធ្វើបែបនេះមិនត្រឹមត្រូវទេ សូមជំទាស់។ សូមអរគុណ។

---

[41] ឯកសារ **E1/250.1** ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥, ទំព័រ ២៦។

កញ្ញា សុង ឆវ័ន្ត៖ លោកប្រធាន ខ្ញុំសូមឆ្លើយតបថា ហើយលោកស្រីសាក្សីបាននិយាយបញ្ជាក់ហើយថា គាត់រៀបការដោយៗមិនពេញចិត្ត ដោយបង្ខំ។ ហើយអីចឹងខ្ញុំគ្រាន់តែសួរបញ្ជាក់ ថាតើខ្ញុំយល់អីចឹងជាការត្រឹមត្រូវដែរឬទេ? អីចឹងសូមឱ្យលោកប្រធានសម្រេចដើម្បីឱ្យខ្ញុំអាចបន្តសំណួរ។

ប្រធានអង្គជំនុំ៖ បាទ សេចក្ដីជំទាស់មានមូលដ្ឋានត្រឹមត្រូវ សមស្រប។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយដែលសួរឡើងដោយ សហព្រះរាជអាជ្ញារងជាតិអម្បាញ់មិញនេះទេ។ លោកស្រីអាចតាំងសំណួរផ្សេងទៀត”[42]។

ឧទាហរណ៍ ទីបី៖

“ស៖ លោកស្រី ចំពោះលោកស្រីវិញ តើគោលបំណងនៃការរៀបការនេះគឺដើម្បីបង្កើតកូនឱ្យអង្គការ។ គេពន្យល់លោកស្រីប្រាប់ថាអីចឹង ឬក៏យ៉ាងម៉េច? តើចំពោះលោកស្រីហ្នឹង គឺមានន័យដែរឬទេ បើគេពន្យល់ប្រាប់លោកស្រីថា អីចឹង ឬម៉េច? ថាដើម្បីបង្កើតកូនឱ្យអង្គការ?

ប្រធានអង្គជំនុំ៖ សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

លោក គង់ សំអុន៖ បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ព្រោះសាក្សីមិនដែលបានឆ្លើយថារៀបការ ដើម្បីបង្កើតកូនឱ្យអង្គការទេ ហើយសំណួរនេះគឺជាសំណួរនាំមុខ។ ដូច្នេះខ្ញុំសូមជំទាស់បាទ។ សូមអរគុណ។

លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖ សូមអរគុណ។ លោកប្រធាន ខ្ញុំមិនសួរនាំមុខទេអម្បាញ់មិញហ្នឹង ខ្ញុំគ្រាន់តែសួរថាគាត់ទទួលអារម្មណ៍យ៉ាងម៉េចដែរ? យើងត្រូវដឹងពីមូលហេតុព្រោះថា ពួកគាត់ទាំងអស់គ្នាត្រូវគេបង្ខំឱ្យរៀបការ។ អីចឹងទាក់ទងនឹងឧក្រិដ្ឋកម្ម ទាក់ទងទៅនឹងការរៀបការដោយបង្ខំនេះ ហើយចៅក្រមអាចធ្វើការសម្រេចតាមខ្លួនយល់ ព្រោះថាខ្ញុំសួរនេះសួរដើម្បីឱ្យឃើញថា តើគាត់នេះជាសាក្សីនេះគាត់មានទទួលអារម្មណ៍យ៉ាងម៉េចដែរ នៅពេលបង្ខំឱ្យរៀបការហ្នឹង?

ប្រធានអង្គជំនុំ៖ សំណួរបើជាភាសាខ្មែរ គឺមានន័យខ្លឹមសារគឺនាំមុខហើយ។ អីចឹងការជំទាស់ហ្នឹងសមស្រប។ អីចឹងដើម្បីឱ្យច្បាស់លាស់ ដោយមានបញ្ហាអ្នកស្ដាប់ភាសាអង់គ្លេស ចៅក្រមហ្នឹងគឺ

[42] ឯកសារ **E1/254.1** ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥, ទំព័រ ១៧ ដល់ ១៨។

គាត់យល់ថាសំណួរហ្នឹងសមស្រប ប៉ុន្តែយើងជាភាសាខ្មែរយល់ថាសំណួរនេះមិនអនុញ្ញាតឲ្យឆ្លើយទេ ដោយសារមូលហេតុជាសំណួរនាំមុខ។ អ៊ីចឹងសូមលោកស្រីមេធាវីរៀបចំសំណួរអម្បាញ់មិញនេះសារជាថ្មីម្តងទៀត”[43]។

ឧទាហរណ៍ ទីបួន៖

“ស៖ ឯកសារទាំងអស់ដែលខ្ញុំបានបង្ហាញ ពីឃុំចំនួនបួននៅស្រុកត្រាំកក់នោះ គឺជាឯកសារដែលធ្វើឡើងនៅក្នុងខែតែមួយ គឺក្នុងខែ ឧសភា ដល់ខែ មេសា ឆ្នាំ ៧៧។ តើឯកសារទាំងបួនហ្នឹងធ្វើឲ្យលោកនឹកឃើញអំពីពេលវេលានៃការចូលរួមក្នុងកិច្ចប្រជុំ ដែលគេផ្តល់ការណែនាំឲ្យបោសសម្អាតមន្ត្រីរដ្ឋការ និងយោធានលន់ នល់ ដែរឬទេ? ហើយតើលោកអាចចាំបានដែរឬទេ ថាតើ ប្រសិនបើធៀបជាមួយនិងខែ មេសា ៧៧ ហ្នឹង តើការប្រជុំណែនាំឲ្យបោសសម្អាតហ្នឹងគេធ្វើនៅមុន ឬក្រោយខែ មេសា ឆ្នាំ ៧៧?

ប្រធានអង្គជំនុំ៖ សាក្សីកុំអាលទានឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

លោក វ៉ិចទ័រ កូប៉េ៖ ខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរនេះ ព្រោះថាវាជាសំណួរនាំមុខ។ វាមិនមែនជាវិធីសាស្ត្រល្អក្នុងការសួរសាក្សី ដែលផ្តល់នូវចម្លើយទាំងអស់អំពីកាលបរិច្ឆេទ បន្ទាប់មកឲ្យសាក្សីគាត់ឆ្លើយថា អះអាងតាមតែប៉ុណ្ណោះ។ សួរថាវាមានប្រយោជន៍អី?

លោក ខេល លីសាក់៖ ខ្ញុំសូមបញ្ជាក់ថា ហេតុផលដែលខ្ញុំផ្តល់ឯកសារដើម្បីឲ្យសាក្សីគាត់យល់ហើយអាចនឹកឃើញ។ ដូច្នេះសំណួរមិនមែនជាការនាំមុខទេ ខ្ញុំគ្រាន់តែសួរថា តើមុនឬក៏ក្រោយខែមេសា ឆ្នាំ ៧៧។ វាមិនមែនជាសំណួរនាំមុខទេ ផ្ទុយទៅវិញគឺវាជាសំណួរមិននាំមុខ។

ប្រធានអង្គជំនុំ៖ បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី។ ហើយអង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សី នៅចំពោះសំណួរចុងក្រោយដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។ សាក្សីឆ្លើយតបទៅនឹងសំណួរ!”[44]។

ឧទាហរណ៍ ទីប្រាំ៖

---

[43] ឯកសារ **E1/254.1** ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥, ទំព័រ ៤៨ ដល់៤៩។

[44] ឯកសារ **E1/278.1** ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥, ទំព័រ ៣៤ ដល់៣៥។

"សះ តើលោកនៅចាំឬទេ ប្រហែលជាខ្ញុំព្យាយាមរំឭកការចងចាំរបស់លោក ថាតើខុម នៅពេលដែលគាត់ត្រឡប់មកវិញ គាត់បាននិយាយទាក់ទងទៅនឹងថាប្រជាជន ដែលស្ថិតនៅក្នុងអតីតរបបលន់ នល់ គឺថាអាចដាក់នៅក្រៅក្របខណ្ឌ គេត្រូវបំបែកអ្នកទាំងនោះ ជាជាងសម្លាប់អ្នកទាំងនោះចោល។ តើធ្លាប់ឮបែបនេះដែរឬទេ?

ប្រធានអង្គជំនុំ៖ បាទ ហើយអង្គជំនុំជម្រះឯកភាពតាមការកត់សម្គាល់ របស់សហព្រះរាជអាជ្ញារងអន្តរជាតិ គឺពិតជាប្រភេទសំណួរនាំមុខ ហើយមានចំនួនច្រើនផងនៅក្នុងការតាំងសំណួរនេះ។ សាក្សីមិនបាច់ឆ្លើយតបនឹងសមណួរដែលសួរនាំមុខអម្បាញ់មិញនេះទេ។ ហើយចំណែកលោកមេធាវី វ៉ិចទ័រ កូប៉េ សូមលោករៀបចំនៅសំណួរសាជាថ្មីម្តងទៀត ជៀសវាងក្នុងការតាំងសំណួរប្រភេទបែបសំណួរនាំមុខ ដែលជាសំណួរហាមឃាត់នៅក្នុងនីតិវិធីតុលាការ"[45]។

ឧទាហរណ៍ ទីប្រាំមួយ៖

"សះ ហើយបើសិនជាទាហានដែលពាក់បណ្តាស័ក្តិប៉ុណ្ណឹង មិនឲ្យមានការប៉ះពាល់ តើមានន័យថាទាហានដែលមានឋានន្តរសក្តិទាបជាងនេះ ក៏មិនត្រូវប៉ះពាល់ដែរ ឬក៏យ៉ាងម៉េច?

លោក ឌេល លីសាក់៖ គាត់សួរនាំមុខសាក្សីទៀតហើយ ដោយគាត់យកពាក្យនេះ មកឲ្យសាក្សីឆ្លើយតែម្តង។

លោក វ៉ិចទ័រ កូប៉េ៖ ការអនុវត្តនៅក្នុងតុលាការនេះ គឺថាខ្ញុំគួរតែត្រូវបានអនុញ្ញាតថា បើសិនជាសួរអីចឹង តើវាបង្កប់ន័យថាយ៉ាងដូច្នេះដែរឬក៏អត់? អីចឹងដូច្នេះ ខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យសួរសំណួរបែបនេះ។

[១០:០២:០២]

ប្រធានអង្គជំនុំ៖ បាទ អង្គជំនុំជម្រះបដិសេធ មិនអនុញ្ញាតឲ្យសួរសំណួរបែបនេះទេ។ សំណួរបែបនាំមុខ ហើយសំណួរបែបនាំឲ្យសាក្សីផ្តល់នូវចម្លើយ បែបការសន្និដ្ឋាននេះ។

---

[45] ឯកសារ **E1/291.1** ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥, ទំព័រ ៥០។

លោក វ៉ិចទ័រ កូប៉េ៖ ខ្ញុំមិនយល់ពីអត្ថន័យនៃសំណួរនាំមុខនោះទេ អីចឹងប្រហែលជាខ្ញុំសួរចម្លើយ។ គឺថា សារចេញពីចម្លើយហ្នឹង គឺគ្រាន់តែយកចម្លើយរបស់សាក្សីម្នាក់ ហើយមកសួរបញ្ជាក់ឡើងវិញតែប៉ុណ្ណោះ តើវាជាសំណួរនាំមុខ ឬក៏យ៉ាងណាទេ? ដូច្នេះខ្ញុំចង់បានការណែនាំពីអង្គជំនុំជម្រះថាតើសំណួរបែបនេះ វាជាសំណួរនាំមុខ ឬក៏អត់នោះទេ។

ប្រធានអង្គជំនុំ៖បាទ ច្បាស់លាស់ អង្គជំនុំជម្រះគិតថាវាជាសំណួរនាំមុខ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសាក្សី ឆ្លើយតបនឹងសំណួរនេះទេ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីការពារក្តី នួន ជាទេ ព្រោះវាជាសំណួរនាំមុខ”[46]។

ឧទាហរណ៍ ទីប្រាំពីរ

“ស៖ ពាក់ព័ន្ធនឹងចំណុចមួយ ដែលលោកស្រីបានលើកឡើងអម្បាញ់មិញនេះ គឺម៉ោងការងារ។ លោកស្រីបានបញ្ជាក់បន្តិចដែរ ហើយខ្ញុំសូមរំឭកឡើងវិញ នៅក្នុងចម្លើយរបស់លោកស្រី ដែលបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត គឺក្នុងឯកសារ D166/38 ត្រង់ ERN ជាភាសាខ្មែរ 00239930, ជាភាសាអង់គ្លេស 00244164, ជាភាសាបារាំង 00283909។ លោកស្រីបានឆ្លើយថា “ចាប់ផ្តើមធ្វើការពីម៉ោងបីជិតភ្លឺ រហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់។ រួចចាប់បន្តពីម៉ោងមួយរសៀល រហូតដល់ម៉ោងប្រាំល្ងាច និងពេលយប់ពីម៉ោងប្រាំមួយ ដល់ម៉ោងដប់ពីរកណ្តាលអធ្រាត”។ បើតាមអ្វីដែលលោកស្រីបានលើកឡើងឃើញថា នៅពេលថ្ងៃ នៅពេលព្រឹកលោកស្រីធ្វើការប្រាំបួនម៉ោង និងពេលយប់រយៈពេលប្រាំម៉ោង សរុបទាំងអស់ ១៨ ម៉ោង។ ពាក់ព័ន្ធករណីនេះ ខ្ញុំចង់សួរលោកស្រីថា តើដោយសារតែម៉ោងការងារនេះហើយ ដែលលោកស្រីបញ្ជាក់ថា ជាសមរភូមិក្តៅ?

[១១:៣១:៥១]

ប្រធានអង្គជំនុំ៖ សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី គង់ សំអុន!

លោក គង់ សំអុន៖ បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ព្រោះវាជាសំណួរនាំមុខ។ បាទ សូមអរគុណ។

[46] ឯកសារ **E1/292.1** ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥, ទំព័រ ១៦ ដល់១៧។

លោក ស្រ៊ា រតនៈ៖ ខ្ញុំគិតថា សំណួរនេះមិនជាសំណួរនាំមុខទេ ដោយសារមុននេះលោកស្រីគាត់បានបញ្ជាក់រួចហើយថា សមរភូមិក្តៅ ដោយធ្វើការចាប់ផ្តើមពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន។ អីចឹងអ្វីដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ គ្រាន់តែសួរបញ្ជាក់បន្ថែមតែប៉ុណ្ណោះ។

ប្រធានអង្គជំនុំ៖ បាទ សេចក្តីជំទាស់របស់មេធាវីការពារក្តីខៀវ សំផន សមស្របហើយ ជាសំណួរនាំមុខ។ លោកអាចរៀបចំនូវសំណួរនេះ សាជាថ្មីម្តងទៀត”[47]។

27. សហមេធាវីនាំមុខលើកឡើងថា មេធាវីការពារក្តីមិនបានបង្ហាញថា តើការអនុវត្តបច្ចុប្បន្នពាក់ព័ន្ធនឹងសំណួរនាំមុខ មិនបានបំពេញចំណុចសំខាន់នៃសំណើដោយរបៀបណាទេ។ ចំពោះអង្គហេតុដែលថា ការអនុវត្តនេះបានចងកាតព្វកិច្ចភាគីទាំងអស់ស្មើៗគ្នា សំណើនេះមិនបានបង្ហាញថាតើការអនុវត្តដែលមាននាពេលបច្ចុប្បន្នធ្វើនេះ បានបង្កព្យសនកម្មបែបណាដល់មេធាវីការពារក្តីទេ។ ហេតុដូច្នេះ សហមេធាវីនាំមុខលើកឡើងថា ការអនុវត្តដែលមាននាពេលបច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ស្របតាមវិធាន ៩១(១) ៩១(៣) ដោយអានជាមួយនឹងវិធាន ៨៥ និង៨៧(៣) នៃវិធានផ្ទៃក្នុង ដោយរក្សានូវតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់។

28. មេធាវីការពារក្តីបានស្នើបន្ថែមទៀតដល់អង្គជំនុំជម្រះសាលាដំបូង ឲ្យហាមឃាត់ភាគីនានាមិនឲ្យអានសម្រង់ចេញពីកំណត់ហេតុស្តាប់ចម្លើយកន្លងមករបស់ពួកគេ ដើម្បីអះអាងពីភាពពិតប្រាកដនៃសម្រង់ទាំងអស់នោះ ដោយមេធាវីការពារក្តីបានបន្ថែមទៀតថា កំណត់ហេតុស្តាប់ចម្លើយកន្លងមករបស់សាក្សី គួរត្រូវបានអនុញ្ញាតឲ្យប្រើសម្រាប់តែការពិនិត្យទៅលើភាពអាចជឿជាក់បានរបស់សាក្សី និងដើម្បីបង្ហាញពីភាពខុសគ្នារវាងចម្លើយផ្សេងៗប៉ុណ្ណោះ។

29. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់អំពីការប្រើប្រាស់ចម្លើយកន្លងមកក្នុងពេលសួរដេញដោល ដើម្បីគ្រាន់តែបញ្ជាក់អំពីការពិតនៃខ្លឹមសាររបស់ចម្លើយទាំងនោះតែប៉ុណ្ណោះ[48]។ ការ

---

[47] ឯកសារ **E1/304.1** ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥, ទំព័រ ៤២ ដល់៤៣។

[48] ពង្រាងប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ (ភាសាបារាំង), ទំព័រ ៥១៖ *“La Chambre de première instance comprend la recommandation formulée par la Chambre de la Cour suprême comme tendant à éviter une pratique générale durant l'interrogatoire d'un témoin ou d'une partie civile qui consisterait à citer de façon répétée et extensive les déclarations faites précédemment par la personne entendue - et ceci, effectivement, n'est pas une façon appropriée de conduire un interrogatoire. Cependant, pour des raisons limitées, notamment pour rafraichir la mémoire d'un témoin ou d'une partie civile, ou pour mettre à l'épreuve sa crédibilité, il est possible de se référer et de citer des déclarations faites précédemment par la personne entendue. Toutefois, il faut que ceci soit dit clairement, et, pour cette raison, il serait bon que, par exemple, la dernière question formulée par l'avocat des parties civiles soit reformulée afin de faire apparaitre clairement quel est l'objectif de cette citation.*

អនុវត្តនាពេលបច្ចុប្បន្នអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយកន្លងមក ដើម្បីសួរដេញដោលសាក្សី និង/ឬ រម្លឹកការចងចាំរបស់សាក្សី[49]។ សហមេធាវីនាំមុខលើកឡើងថា ការអនុវត្តនេះស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន ៩១ និងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដោយសារតែការអនុវត្តនេះមិនធ្វើឲ្យមានការបង្ហាញភស្តុតាងដដែលៗ[50] នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយអាចជួយដល់ការអនុវត្តប្រកបដោយប្រសិទ្ធិភាពក្នុងកិច្ចដំណើរការនីតិវិធី។

30. យ៉ាងណាក៏ដោយ សហមេធាវីនាំមុខពិចារណាឃើញថា ដោយការសួរសំណួរនាំមុខត្រូវបានភ្ជាប់ជាមួយនឹងការប្រើប្រាស់ចម្លើយកន្លងមកនៅក្នុងតុលាការ[51] នេះគឺជាបញ្ហាដាច់ដោយឡែក ហើយជាបញ្ហាដែលទទួលបានផលប្រយោជន៍ពីការបញ្ជាក់បន្ថែមពីអង្គជំនុំជម្រះសាលាដំបូង។

## IV. សំណើ

---

*Voilà. Donc, en l'occurrence, je pense qu'il serait clair... il serait important qu'il soit clair pour tout le monde que l'objectif était de demander à la partie civile si elle se souvient d'avoir dit ce qui a été lu et si cela correspond effectivement à ce qu'il a effectivement en mémoire. Donc, peut-être que ceci pourrait être la pratique suivie pour l'avenir.*"

[49] *ដូចដើងទំព័រខាងលើ*

[50] *សូមមើលជាឧទាហរណ៍* ឯកសារ **E1/250.1** ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥, ទំព័រ ២០ ដល់២១។ ឯកសារ **E1/261.1** ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥, ទំព័រ ២៨។ ឯកសារ **E1/267.1** ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ ៨២ ដល់៨៣។ ឯកសារ **E1/279.1** ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥, ទំព័រ ៦៥ ដល់៦៦។

[51] សូមមើលជាឧទាហរណ៍ ពង្រាងប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥ ទំព័រ ៦៣ ដល់៦៤៖ លោកប្រធាន៖ "បាទ ឥឡូវហ្នឹង អង្គជំនុំជម្រះសូមជម្រាបជូនភាគីថា ក្នុងករណីនេះវាបញ្ហាដដែលៗ ហាក់ដូចជាការគ្រប់គ្រងសវនាការក៏ជួបនឹងបញ្ហាដែរ ព្រោះរឿងវាមិនមែនជារឿងតូចដែលងាយក្នុងការគ្រប់គ្រងទេ ប៉ុន្តែដើម្បីឲ្យបានច្បាស់លាស់គឺសូមឲ្យភាគីពាក់ព័ន្ធគឺតាំងសំណួរបើកជាមុនសិន។ ចំពោះសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ឬក៏គោលដៅណាដែលខ្លួនសួរ ហើយក្នុងករណីខ្លួនចម្លើយតបរបស់មេ របស់គោលដៅដែលបានសួរនោះ ឯងវាមានការខុស ឬក៏ផ្ទុយគ្នាទៅនឹងកំណត់ហេតុដែលខ្លួន ដែលគាត់បានផ្តល់សក្ខីកម្មលើកមុន នោះគឺទើបសំណួរបន្ទាប់មកទៀតអាចលើកយកដកស្រង់នូវកំណត់ហេតុដែលគាត់ឆ្លើយពីមុនៗ ផ្តល់សក្ខីកម្មពីមុនៗមកផ្ទៀងផ្ទាត់ជាមួយនឹងចម្លើយរបស់គាត់ដែលគាត់បានឆ្លើយចុងក្រោយដើម្បីបញ្ជាក់ នេះជាការច្បាស់លាស់ជាង។ ទី ២ គឺយើងកត់សម្គាល់ឃើញថាបញ្ហាមួយទៀតដែលប្រឈមនឹងការបញ្ហានោះ ប្រសិនបើអាននូវកំណត់ហេតុស្តាប់ចម្លើយដែលមានពីមុនមកតែម្តងនោះ វានឹងអាចមានបញ្ហា វាប្រហាក់ប្រហែលគ្នា ឬក៏វាខិតជិតគ្នាទៅនឹងសំណួរដឹកមុខ សំណួរនាំមុខ។ ដូច្នេះ យល់ទេ ឥឡូវហ្នឹង សូមសំណួររៀបចំសំណួរឡើងវិញគឺសូមឲ្យរៀបចំសំណួរបើក ហើយប្រសិនមានបញ្ហាផ្ទុយគ្នា ដើម្បីចង់សួរច្បាស់លាស់នោះគឺអាចសួរបញ្ជាក់ដោយដកស្រង់ផ្ទៀងផ្ទាត់ជាមួយនឹងចម្លើយដែលបានឆ្លើយនៅក្នុងកំណត់ហេតុមុនៗ"។

អាស្រ័យហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

(១) ច្រានចោលសំណើពាក់ព័ន្ធនឹងការពិនិត្យលើចម្លើយពីមុនៗដោយសាក្សី ។

(២) សម្រេចថា ការអនុវត្តបច្ចុប្បន្នរបស់អង្គជំនុំជម្រះដែលតម្រូវឲ្យភាគីសួរសំណួរដែលមិននាំមុខ ហើយដែលការអនុវត្តបែបនេះផ្តល់ឱកាសដល់ភាគីធ្វើការជំទាស់ដោយមានមូលហេតុពិតប្រាកដពិតជាឆ្លើយតបទៅនឹងគោលដៅនៃសំណើរ និង

(៣) ផ្តល់ការបញ្ជាក់អំពីការណែនាំ ឬការប្រើប្រាស់ចម្លើយកន្លងមក ក្នុងពេលសាកសួរសាក្សី។

ដោយសេចក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |